# ប្រភពនៃទស្សនវិជ្ជាអប់រំ៖ មនោនិយម និងតថនិយម

*ដោយ៖* **បណ្ឌិត សូ សុធីរ**
*មន្ត្រីស្រាវជ្រាវនាយកដ្ឋានវិទ្យាសាស្ត្រអប់រំ*
*នៃវិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម*
*រាជបណ្ឌិត្យសភាកម្ពុជា*

## សេចក្តីផ្តើម

*គ្រូបង្រៀនត្រូវតែបំពេញតម្រូវការប្រចាំថ្ងៃជាបន្ទាន់ ដូចជាការរៀបចំមេរៀន ការវាយតម្លៃការអនុវត្តរបស់សិស្ស ការបង្កើត និងគ្រប់គ្រងបរិយាកាសក្នុងថ្នាក់រៀនដោយយុត្តិធម៌ និងសមធម៌។ ដោយសារតែភាពបន្ទាន់ បញ្ហាប្រឈមទាំងនេះ អាចរំខានដល់គ្រូបង្រៀននៅដំណាក់កាលដំបូងអាជីពវិជ្ជាជីវៈរបស់ពួកគេពីការបង្កើតអ្វីដែលស្គង់ដាហៅ"ក្របខ័ណ្ឌគំនិត" ដែលជាទស្សនវិជ្ជានៃការអប់រំដែលផ្តល់អត្ថន័យដល់ការបង្រៀនដោយភ្ជាប់តម្រូវការប្រចាំថ្ងៃរបស់វា។ ជាមួយនឹងការប្តេជ្ញាចិត្តប្រកបដោយវិជ្ជាជីវៈរយៈពេលវែង និងទិសដៅ។1 គំនិតក្របខ័ណ្ឌរួមចំណែកដល់អារម្មណ៍នៃភាពស៊ីសង្វាក់គ្នានៃវិជ្ជាជីវៈដែលជួយគ្រូបង្រៀនដាក់គោលដៅរយៈពេលខ្លីភ្ជាមៗទៅក្នុងទំនាក់ទំនងជាមួយគោលដៅរយៈពេលវែង។*

*នៅក្នុងការលើកទឹកចិត្តគ្រូប ង្រៀនឱ្យក្លាយជាអ្នកអនុវត្តការឆ្លុះបញ្ចាំងការអប់រំជឿនលឿន ស្គង់ដាពិពណ៌នាអំពីការបង្រៀនជាដំណើរការថាមវន្តដែលរក្សាការរំពឹងទុកត្រូវបានបំប្លែងទៅជាការអនុវត្តប្រកបដោយអត្ថន័យដែលសង្កត់ធ្ងន់លើចំណេះដឹងទំនួលខុសត្រូវ និងការអនុវត្តជារួម។ ដើម្បីក្លាយជាអ្នកអនុវត្តបែបវិចារ ដែលមានន័យថាគ្រូត្រូវការគិតទស្សនវិជ្ជាអំពីផលប៉ះពាល់វប្បធម៌និងការអនុវត្តសីលធម៌ ទូលំទូលាយអំពីការអប់រំ។*

*យើងអាចកំណត់ទស្សនវិជ្ជាជាវិធីគិតទូទៅបំផុត។ អំពីអត្ថន័យនៃជីវិតរបស់យើងនៅក្នុងពិភពលោក ហើយឆ្លុះបញ្ចាំងយ៉ាងស៊ីជម្រៅអ្វីដែលពិតឬមិនពិត ល្អឬអាក្រក់ ខុស ឬត្រូវ និងស្អាតឬអាក្រក់។ គ្រូទទួលបានក្របខ័ណ្ឌគំនិត ផែនទីទស្សនវិជ្ជា និងទ្រឹស្តី ដែលអ្នកអាចឆ្លុះបញ្ចាំងពីគំនិតរបស់អ្នកអំពីការអប់រំ និងបង្កើតទស្ស នវិជ្ជានៃការអប់រំផ្ទាល់ខ្លួនរបស់អ្នក។*

## ១-វាក្យស័ព្ទវិទ្យាពិសេស

គ្រប់វិស័យនៃការស្រាវជ្រាវ សុទ្ធតែមានវាក្យសព្ទវិទ្យាពិសេស។ ទស្សនវិជ្ជាអប់រំបានប្រើប្រាស់វាក្យសព្ទមូលដ្ឋាន ដូចជា បរមត្ថវិទ្យា (Metaphysics) ពុទ្ធិវិទ្យា (Epistemology) តម្លៃវិទ្យា (Axiology) និងតក្កវិជ្ជា (Logic)។

### ក-តថភាព និងអត្ថិភាព

បរមត្ថវិទ្យាសិក្សាអំពីធម្មជាតិនៃតថភាពកម្រិតខ្ពស់បំផុត។ អ្វីពិត និងអ្វីមិនពិត? តើមានវិស័យអត្ថិភាពចិត្តដោយឡែកពីពិភពសម្ភារៈឬទេ?

ឧទាហរណ៍ ពួកមនោនិយម មើលឃើញតថភាពជាបឋម ក្នុងវាក្យសព្ទខាងផ្លូវចិត្តអរូបី ឬមិនមែនជាសម្ភារៈ។ ពួកតថនិយមមើលឃើញវាថាជាលំដាប់លំដោយជាសត្យានុម័ត ដែលកើតមានដោយឯករាជ្យពីមនុស្សជាតិ។ ការបង្រៀនជាច្រើន នៅតាមសាលារៀន តំណាងឱ្យការខិតខំប្រឹងប្រែងនៃអ្នករៀបចំកម្មវិធីសិក្សា គ្រូបង្រៀន និងអ្នកនិពន្ធសៀវភៅ ដើម្បីពណ៌នាតថភាពទៅដល់សិស្ស។ ក្នុងនាមជាគ្រូបង្រៀន អ្នកនឹងដឹងថា សៀវភៅខុសៗគ្នា មានការបកស្រាយតាមបែបប្រកួតប្រជែងពីតថភាព ឬយ៉ាងហោចណាស់ វាក៏ជាការគូសបញ្ជាក់ភាពខុសគ្នាដែរ។

### ខ-ពុទ្ធិវិទ្យា

ការចេះដឹង និងទ្រឹស្ដីនៃចំណេះដឹងដែលយកចិត្តទុកដាក់ពីចំណេះដឹង និងការយល់ដឹងនោះជះឥទ្ធិពលដល់វិធីបង្រៀន និងរៀន។ វាលើកឡើងនូវសំណួរទាំងឡាយ ដូចជា តើយើងពឹងផ្អែកចំណេះដឹងពីពិភពលោក និងការយល់ដឹងពីសច្ចភាពទៅលើអ្វី? តើចំណេះដឹងរបស់យើង បានទទួលពីការបញ្ចេញឱ្យដឹងនៃអាទិទេពពីគំនិត ដែលមិនទាន់បង្ហាញឱ្យឃើញនៅក្នុងចិត្តរបស់យើង ផ្ទាល់ពីកស្តុតាង តាមបែបសង្កេតពិសោធ ឬពីអ្វីមួយផ្សេងទៀតឬទេ? ជាថ្មីម្ដងទៀត ទស្សនវិជ្ជាផ្សេងៗគ្នា យល់ឃើញគំនិត ដែលទាក់ទងនឹងការចេះដឹង និងទ្រឹស្ដីនៃចំណេះដឹងខុសៗគ្នា។

គ្រូបង្រៀន ដែលជឿជាក់ថា គំនិតមនុស្សគួរតែអនុលោមទៅតាមរចនាសម្ព័ន្ធនៃតថភាព តាមលំដាប់លំដោយ នឹងគូសបញ្ជាក់ តាមលំដាប់លំដោយ និងការបង្រៀននៃមុខវិជ្ជា ទៅតាមលំដាប់លំដោយ។ ផ្ទុយទៅវិញ គ្រូដែលជឿជាក់ថា លំនាំ (របៀបដែលយើងដឹង) វាមានសារៈសំខាន់ជាងខ្លឹមសារ (អ្វីដែលយើងដឹង) នឹងសង្កត់ន័យដល់ការសង្កេត ឬការដោះស្រាយបញ្ហា។

### គ-អ្វីទៅដែលមានតម្លៃ?

**តម្លៃវិទ្យា**ដែលបានរៀបរាប់ពីតម្លៃត្រូវបានគេបែងចែកទៅជាសីលវិជ្ជានិងសោភណវិទ្យា (Aesthetics)។

**សីលវិជ្ជា** សិក្សាអំពីតម្លៃខាងសីលធម៌ និងក្បួនច្បាប់នៃឥរិយាបថដ៏ត្រឹមត្រូវ។ សោភណវិទ្យា និយាយដល់តម្លៃសោភណភាព (Beauty) និងសិល្បៈ។ ថាតើសាលារៀនមួយ បង្រៀនជាក់លាក់នូវតម្លៃ ឬមិននោះ គ្រូបង្រៀន ក៏ដូចជាឪពុកម្តាយ និងសង្គមក្នុងន័យជាទូទៅ បង្ហាញឱ្យឃើញតម្លៃជាក់លាក់ តាមការផ្តល់រង្វាន់ ឬការដាក់ទណ្ឌកម្មដល់អាកប្បកិរិយា ដោយផ្អែកទៅលើថា តើវាអនុលោមទៅតាមគំនិតរបស់ពួកគេ ពីអ្វីដែលត្រឹមត្រូវ ល្អ និងល្អស្អាត។ ជាងនេះទៀត បរិយាកាសសាលារៀនទាំងមូល បង្ហាញតម្លៃសហគមន៍ ដែលមានការអប់រំ។

**ឃ-ការគិតតាមអនុមានញែក និងអនុមានរួម**

តក្កវិទ្យា ដែលពាក់ព័ន្ធនឹងការគិតដ៏រឹងមាំ និងត្រឹមត្រូវនោះ ពិនិត្យមើលក្បួនច្បាប់នៃការបង្កើតគំនិតពីការពិត ដែលជួយយើងធ្វើពង្រាងដ៏ត្រឹមត្រូវនូវសំណើ និងការអះអាង។ តក្កវិទ្យាអនុមាណញែក (Deductive logic) ចេញពីការអះអាងជាទូទៅ ទៅរកការអនុវត្ត និងឧទាហរណ៍ពិសេស។ តក្កវិទ្យាអនុមានរួម (Inductive logic) ចេញពីឧទាហរណ៍ពិសេស ទៅរកប្រធានបទទូទៅនីយកម្ម ដែលជាការស្ទង់មើល ដើម្បីការផ្ទៀងផ្ទាត់បន្ថែម។

កម្មវិធីសិក្សា និងការបង្រៀន ត្រូវបាន រៀបចំតាមបញ្ញត្តិនៃតក្កវិជ្ជា។ តើអ្វីមួយ នៅក្នុងមុខវិជ្ជាតម្រូវពីរបៀប ដែលមេរៀនគួរតែ ត្រូវបានគេរៀបចំ និងបង្ហាញសិស្ស (គោលវិធីអនុមានញែក)? ឬគ្រូបង្រៀន គួរតែទទួលយកសញ្ញាបង្ហាញប្រាប់ផ្លូវពីចំណូលចិត្ត ភាពត្រៀមខ្លួនជាស្រេច និងបទពិសោធរបស់សិស្ស ក្នុងការសម្រេចចិត្តពីរបៀបបង្ហាញការបង្រៀន (គោលវិធីអនុមានរួម)?

ជាមួយនឹងប្រវត្តិវាក្យសព្ទវិទ្យា យើងអាចពិនិត្យមើលទស្សនវិជ្ជា និងទ្រឹស្តីផ្សេងៗគ្នា។ ក្រោយពេលពិភាក្សាបញ្ញត្តិគន្លឹះនីមួយៗ យើងអាចមើលឃើញពីរបៀប ដែលវាឆ្លើយតបទៅនឹងសំណួរមូលដ្ឋាន នៅដើមនៃជំពូក និងជួយគ្រូបង្រៀនម្នាក់ ជួយបង្កើតទស្សនវិជ្ជាអប់រំ ។

**ទំនាក់ទំនងទស្សនវិជ្ជា នៅនឹងការអប់រំ ការបែងចែកមុខវិជ្ជារងនៃទស្ស នវិជ្ជា និងភាពពាក់ព័ន្ធនឹងការអប់រំ**

-**បរមត្ថវិទ្យា** អ្វីជាតថៈ?

**ចំណេះដឹងដ៏មានតម្លៃបំផុត** កម្មវិធីសិក្សា

-**ពុទ្ធិវិទ្យា** តើចំណេះដឹងពឹងផ្អែកទៅលើអ្វី?

**របៀបដែលយើងបង្រៀននិងរៀន** វិធីបង្រៀន

-**តម្លៃវិទ្យា**

អ្វីជាសីលធម៌និងភាពត្រឹមត្រូវ? អ្វីជាសោភណវិទ្យា និងសិល្បៈ?

**ការអប់រំ** អាកប្បកិរិយា អត្តចរិត សេចក្តីគួរសម និងការបង្ហាញអារម្មណ៍តាមទឹកមុខ

-**តក្កវិជ្ជា** យើង អាចធ្វើវិចារយ៉ាងដូចម្តេច?

**ការអប់រំ** របៀបដែលយើងរៀបចំ និងធ្វើរចនាសម្ព័ន្ធមុខវិជ្ជា មេរៀន។

## ២-មនោនិយម

**អ្នកផ្ដើមគំនិតមនោនិយមគួរឱ្យកត់សម្គាល់**

*មនោនិយម ដែលជាទស្សនវិជ្ជាតាមប្រពៃណី មានចំណាស់ជាងគេមួយនោះ និយាយយោងដល់* **ប្លាតុង** *ដែលបានអភិវឌ្ឍគោលការណ៍មនោនិយម ក្នុងក្រុងអាថែនបុរាណ។ នៅប្រទេសអាល្លឺម៉ង់* Georg W. F. Hegel *បានបង្កើតទស្សនៈពិភពលោកយ៉ាងទូលំទូលាយ ដោយផ្អែកទៅលើមនោនិយម ហើយនៅសហរដ្ឋអាម៉េរិក* Ralph Waldo Emerson *និង* Henry David Thoreau *បានអភិវឌ្ឍមនោនិយមច្រើនបែបផ្សេងៗគ្នា ដែលគេបានស្គាល់ថាជាអតិសេដ្ឋនិយម* (Transcendentalism)*។*

Friedrich Froebel *ពឹងផ្អែកទ្រឹស្ដីអប់រំមត្តេយ្យរបស់គាត់ទៅលើមនោនិយម*[1]*។*

*សាសនានៅអាស៊ី ដូចជាព្រហ្មញ្ញសាសនា និងពុទ្ធសាសនា ក៏បានពឹងផ្អែកផងដែរនូវទស្សនវិស័យខាងស្មារតី ដោយបានផ្សារភ្ជាប់ទៅនឹងមនោនិយម។*

### ២-១-បញ្ញត្តិគន្លឹះ

**ក-សច្ចភាពអនន្ត សកល**

**បរមត្ថវិទ្យា** *ពួកមនោនិយម ជឿជាក់ថា មានតែចិត្ត ឬស្មារតី ដែលជាតថភាពកម្រិតកំពូល។ ពួកគេយល់ឃើញថា ចក្រវាឡដែលបញ្ជាក់បង្ហាញនៃបញ្ញា និងឆន្ទៈ ដែលបានធ្វើទូទៅកម្មកម្រិតខ្ពស់ គឺជាចិត្តសកល។ ខ្លឹមសារខាងស្មារតីរបស់បុគ្គល ឬព្រលឹង គឺជាទិដ្ឋភាពអចិន្ត្រៃយ៍នៃធម្មជាតិ មនុស្សដែលផ្ដល់ភាពក្លៀវក្លា និងថាមភាព។ ពិភពគំនិតគឺអនន្ត អចិន្ត្រៃយ៍ ទៀងទាត់ និងមានលំដាប់លំដោយ។ សច្ចភាព និងតម្លៃ គឺមានភាពដាច់ខាត និងសកល។*

**ខ-សារព័នសាកល និងកំណែប្រែថ្មី តាមខុទ្ទកភាព**

*ពួកមនោនិយម ដូចជាពួកអតិសេដ្ឋនិយម ប្រើប្រាស់សារព័នសាកល និងកំណែប្រែថ្មីតាមខុទ្ទកភាព ដើម្បីពន្យល់កំណែប្រែថ្មីនៃសច្ចភាព។*

**សារព័នសាកល** *និយាយយោងទៅដល់ចិត្តសាកល បុព្វហេតុបឋម អ្នកបង្កើតលោក ឬអាទិទេព។ ដោយមិនបានគិតដល់ឈ្មោះពិសេស ដែលបានប្រើនោះ ចិត្តដែលទាក់ទងទៅនឹងសារព័នសាកល ជាអត្ថិភាពទាំងស្រុង ឬទាំងមូល។ វាគឺមានតែមួយ រាប់បញ្ចូលទាំងអស់ និងអត្តពេញលេញ ដែលអត្តទាំងអស់ជាផ្នែកតូចជាង គឺជាផ្នែកទាំងឡាយ។ ចិត្តសាកលសារព័នសាកល គឺជាការគិត និងការវាយតម្លៃជាបន្តបន្ទាប់ ឬឥតដាច់។*

*សារព័នសកល គឺជាផ្នែកដែលមានដែនកំណត់មួយនៃផ្នែកទាំងមូល ជាបុគ្គល*

[1] Gerald L. Gutek, *Philosophical and Ideological Voices in Education* (Boston: Allyn and Bacon, 2004), pp.15-27.

*និងអត្ត ដែលតូចជាង។ ប៉ុន្តែ កំណែប្រែថ្មីតាមខុទ្ទកភាព មានសារធាតុខាងស្មារតីដូចគ្នាទៅនឹងសារព័នសាកល។*

**គ-ចំណេះដឹង ដែលមិនទាន់បង្ហាញឱ្យឃើញ**

**ពុទ្ធិវិទ្យា** *មនោនិយម បានសង្កត់ធ្ងន់លើការទទួលបានចំណេះដឹង ឬការចងចាំនូវបទពិសោធនៃគំនិត ដែលមិនទាន់បញ្ចេញឱ្យឃើញ គឺផ្នែកទាំងឡាយ ដែលបានបង្ហាញ ប៉ុន្តែ មិនទាន់ជាញាណ នៅក្នុងចិត្ត។ គំនិតមានពីមុនទាំងនេះ ពាក់ព័ន្ធដល់ចំណេះដឹងដែលបានកើតឡើងពីពេលមុន និងឯករាជ្យពីបទពិសោធរបស់មនុស្ស អំពីពួកគេ។ តាមរយៈអត្តាពិគ្រោះ បុគ្គល បានពិនិត្យមើលចិត្តផ្ទាល់ខ្លួន ហើយរកឃើញការត្រាប់តាមនៃចិត្តសារព័នសាកល។ ការបញ្ចេញសមត្ថភាពរបស់គ្រូ ដើម្បីនាំយកចិត្ត ដែលមិនទាន់បង្ហាញឱ្យឃើញទៅជាញាណ។ ហេតុដូច្នោះហើយ ការអប់រំជួយឱ្យសិស្សបានឈានដល់ទស្សនវិស័យ នៃចក្រវាឡប្រកបដោយឯកភាវូបនីយកម្ម ទូទៅ និងទូលំទូលាយ[2]។*

**ឃ-ឋានានុក្រមនៃមុខវិជ្ជា**

*គ្រូបង្រៀនបែបមនោនិយមពេញចិត្តកម្មវិធីសិក្សាតាមឋានានុក្រមជាង ដោយបានពឹងផ្អែកលើមុខវិជ្ជា ឬបញ្ហាកម្មវត្ថុមុខវិជ្ជាតាមបែបប្រពៃណី។ នៅផ្នែកកំពូលគេនៃឋានានុក្រម ជាមុខវិជ្ជាទូទៅបំផុត គឺទស្សនវិជ្ជា និងសាសនវិជ្ជា។ មុខវិជ្ជាអរូបី និងទូទៅទាំងនេះ មានលក្ខណៈលុបទៅលើដែនកំណត់នៃពេលវេលា ទីកន្លែងនិងកាលៈទេសៈ និងវាផ្លាស់ប្តូរទៅតាមស្ថានភាពដ៏ទូលំទូលាយ។ គណិតវិទ្យា ក៏មានតម្លៃផងដែរ ពីព្រោះវាបណ្តុះថាមពល ដើម្បីដោះស្រាយជាមួយការគិតអរូបី។ ប្រវត្តិវិទ្យា និងអក្សរសិល្ប៍ មានកម្រិតខ្ពស់ ដែលជាប្រភពនៃគំរូទាំងឡាយខាងវប្បធម៌ និងសីលធម៌។ ផ្នែកទាបបន្តិចក្នុងកម្មវិធីសិក្សានោះ គឺវិទ្យាសាស្ត្រខាងរាងកាយ និងធម្មជាតិ បញ្ជាក់នូវទំនាក់ទំនងពិសេសខាងហេតុផល។ ភាសា មានសារៈសំខាន់ ពីព្រោះវាមានឧបករណ៍ចាំបាច់ផងដែរ នៅគ្រប់កម្រិតទាំងអស់នៃការសិក្សា។ សម្រាប់ពួកមនោនិយម កម្រិតនៃចំណេះដឹងខ្ពស់បំផុត ទទួលស្គាល់នូវទំនាក់ទំនង ក្នុងចំណោមកម្មវត្ថុមុខវិជ្ជាទាំងនេះ និងធ្វើសមាហរណកម្មវា។*

**ខ-តម្លៃដែលនៅស្ថិតស្ថេរ**

**តម្លៃវិទ្យា** *ដោយសារតែពួកមនោនិយមមើលឃើញចក្រវាឡក្នុងលក្ខខណ្ឌអនន្តនិងសាកលនោះ គេបានបញ្ញត្តតម្លៃ ដែលមិនអាចផ្លាស់ប្តូរ និងអាចអនុវត្តបាន ចំពោះមនុស្សទាំងអស់។ អាកប្បកិរិយាខាងសីលវិជ្ជាឆ្លុះបញ្ចាំងនូវចំណេះដឹង ដែលស្ថិតស្ថេរ និង*

[2] Gerald L. Gutek, *Philosophical and Ideological Perspectives on Education*, 2nd ed. (Boston: Allyn and Bacon, 19997), pp.13-25.

តម្លៃនៃវប្បធម៌មនុស្ស។ ទស្សនវិជ្ជា សាសនវិទ្យា ប្រវត្តិវិទ្យា អក្សរសិល្ប៍ និងសិល្បៈ ជាប្រភពដ៏សម្បូរបែប សម្រាប់ផ្ទេរមរតកនៃតម្លៃនេះ។ ការអប់រំបែបនេះ ទាមទារថា សិស្សជួបប្រទះគំរូដ៏មានតម្លៃ ជាពិសេសស្នាដៃ ដែលបានស្ថិតស្ថេរក្នុងអំឡុងពេលមួយ។

**ច-ភាពមិនផ្លាស់ប្តូរបែបតក្កវិទ្យា**

**តក្កវិទ្យា** សម្រាប់ពួកមនោនិយម តក្កវិទ្យា ពឹងផ្អែកទៅលើទំនាក់ទំនងពីភាពពេញលេញ ទៅជាផ្នែកៗ ផ្នែកតូច ដែលជាគំនិត ឬជាគោលការណ៍ពិសេសនោះ គឺក្លាយមកពី និងយល់ស្រប ជាមួយផ្នែកទាំងមូល ដែលមានលក្ខណៈទូទៅជាង។

គ្រូបង្រៀនបែបពួកមនោនិយម គួរតែរៀបចំមេរៀន ដែលមានជាបន្តបន្ទាប់នូវការរៀបចំបែបតក្កវិទ្យាអនុមានញែក ដែលសង្កត់ធ្ងន់នូវគោលការណ៍ឬក្បួនច្បាប់ទូទៅ និងបន្ទាប់មកទាញនូវការពន្យល់ជាក់លាក់ជាងសម្រាប់ពួកគេ។ ជាឧទាហរណ៍ គ្រូបង្រៀនបែបពួកមនោនិយម គួរតែយកមកប្រើប្រាស់បញ្ញត្តិជាទូទៅនៃភាពអហិង្សា មុនពេលពិភាក្សាផលវិបាកនៃការសម្លុត ឬធ្វើបាបមិត្តរួមថ្នាក់របស់ពួកគេ (Bullying one's classmates)។

**២-២-សំណួរជាមូលដ្ឋាន**

**ក-ចំណេះដឹងនៃគំនិតសាកល**

ប្រសិនបើអ្នក សួរទៅគ្រូបែបមនោនិយម អ្វីទៅជាចំណេះដឹង? ពួកគេនឹងឆ្លើយថា ចំណេះដឹង មានការពាក់ព័ន្ធនឹងគោលការណ៍ខាងស្មារតី ដែលបង្កើតបានជាមូលដ្ឋាននៃតថភាព។ ចំណេះដឹងនៃតថភាពនេះ មានទម្រង់ជាគំនិត។ ប្រសិនបើចំណេះដឹង និយាយអំពីគំនិតសកលនោះ ដូច្នេះ ការអប់រំ ជាលំនាំនៃការនាំយកគំនិតខាងបញ្ញាទៅដល់ញាណរបស់សិស្ស។

**ខ-ការសិក្សាអប់រំ៖ ការស្វែងរកសច្ចភាពខាងបញ្ញា**

ប្រសិនបើអ្នកសួរទៅគ្រូមនោនិយម បន្ថែមទៀត អ្វីជាការសិក្សាអប់រំ? គាត់នឹងនិយាយថា សាលារៀនជាស្ថាប័នមួយ ដែលសិស្សស្រាវជ្រាវរក និងបន្តរកសច្ចភាព។ វាជាស្ថាប័នខាងបញ្ញាដែលគ្រូ និងសិស្ស ស្វែងរកសំណួរដែល Socrates និង Plato បានសួរជាលើកដំបូងថា អ្វីជាសច្ចភាព? អ្វីជាសោភណភាព? អ្វីជាជីវិតល្អ? ចម្លើយទាំងនេះ មានវត្តមាន ប៉ុន្តែ ត្រូវបានលាក់កំបាំងក្នុងចិត្តរបស់យើង និងយើងត្រូវតែឆ្លុះបញ្ចាំងយ៉ាងជ្រាលជ្រៅ ដើម្បីនាំពួកគេទៅដល់ញាណរបស់ពួកគេ។ យើង មិនគួរអនុញ្ញាតអ្វីទាំងអស់ ដើម្បីធ្វើឱ្យយើងខ្វល់ពីការតាមរកសច្ចភាពខាងបញ្ញា។

អ្នកណា គួរតែទៅសាលារៀន? ពួកមនោនិយម និយាយថា មនុស្សទាំងអស់គ្នា។ មិនមែនសិស្សទាំងអស់ មានសម្បទាខាងប ញ្ញាដូចគ្នានោះទេ ប៉ុន្តែ មនុស្សទាំងអស់ត្រូវតែបណ្តុះចិត្តរបស់ខ្លួនទៅដល់ដែនកំណត់នៃសមត្ថភាពរបស់គេ។ សិស្សដែល

*មានអំ ណោយផលពីធម្មជាតិ ត្រូវការសមត្ថភាពខាងបញ្ញាខ្ពស់បំផុត ដែលគ្រូអាចផ្តល់ឱ្យ។*

**គ-វិធីសូក្រាត**

*តើយើងគួរបង្រៀនយ៉ាងដូចម្តេច? ពួកមនោនិយម គួរតែនិយាយថា ការគិត និងការសិក្សាជាឈ្មោះ សម្រាប់ដំណើរការនៃការនាំយកគំនិតទៅដល់ញាណ។ មធ្យោបាយដ៏មានប្រសិទ្ធភាពមួយ នៃការអនុវត្តបែបនេះ គឺវិធីតាមបែបសូក្រាត ដែលក្នុងនោះ គ្រូបង្រៀនក្រោចការយល់ដឹងនៃគំនិតរបស់សិស្សដោយការសួរសំណួរនាំមុខ។ ប្រការដ៏សំខាន់មួយផ្សេងទៀតនៃវិធីសាស្ត្រពួកមនោនិយម គឺការធ្វើជាគំរូ។ គ្រូបង្រៀនគួរតែធ្វើជាគំរូដ៏មានតម្លៃដល់ការត្រាប់តាមរបស់សិស្ស គឺគាត់គួរតែមានចំណេះដឹងទូលំទូលាយពីមរតកវប្បធម៌ និងដឹកនាំជីវិតតាមអនុករណ៍* (Examplary lives)។

**ឃ-ស្តង់ដា និងការវាយតម្លៃ**

**ស្តង់ដាកម្រិតខ្ពស់** *ពួកមនោនិយម ចង់ការពារគុណភាពនៃការអប់រំ តាមការរក្សាស្តង់ដាបញ្ញាកម្រិតខ្ពស់ ហើយប្រឆាំងនឹងទំនោរចំពោះភាពបន្ធូរ។ ឧទាហរណ៍ នៅក្នុងស្នាដៃសាធារណរដ្ឋរបស់ប្លាតុង* (Plato's Republic) *ស្តង់ដាបញ្ញា គឺមានកម្រិតខ្ពស់ខ្លាំងរហូតដល់មានតែមនុស្សដែលមានអំណោយផលពីកំណើតតិចតួចប៉ុណ្ណោះ បានចូលចំណាត់ថ្នាក់ជាវរជនដឹកនាំនៃអធិរាជទស្សនវិទូ។ ពួកមនោនិយម នាសម័យបច្ចុប្បន្ននេះ មិនមានការលូតលាស់ខ្លាំងណាស់ណាទេ ប៉ុន្តែ គោលដៅអប់រំរបស់ពួកគេ រាប់បញ្ចូលទាំងការអភិវឌ្ឍសមត្ថភាពខាងបញ្ញា ហើយជាទូទៅ ពួកគេទទួលយកការពិត ដែលថា មិនមែនគ្រប់សិស្សទាំងអស់ នឹងបន្តដល់ដំណាក់កាលខ្ពស់បំផុតនៃការអប់រំទេ។*

*ទោះបីជាពួកមនោនិយម មិនអាចមានទស្សនៈលទ្ធផលតេស្តតាមស្តង់ដា ដូចដែលរង្វាស់នៃការវាយតម្លៃស្នាដៃសិក្សានោះ ពួកគេគួរតែគាំទ្រជាទូទៅនូវចលនា ស្តង់ដាក្នុងការអប់រំ។ សម្រាប់ពួកគេ ស្តង់ដាខ្ពស់ផ្តល់ក្តីសង្ឃឹមខ្ពស់ ទាំងគ្រូ ទាំងសិស្ស។*

**២-៣-ការអនុវត្តសម្រាប់គ្រូបង្រៀនក្នុងថ្នាក់រៀននាពេលបច្ចុប្បន្ន**

**ក-ការអភិវឌ្ឍបញ្ញា មិនមែនការបណ្តុះបណ្តាលវិជ្ជាជីវៈ**

*ដោយបដិសេធវិជ្ជាជីវៈនិយម ដែលតែងតែបង្កើតតម្លៃ នៅក្នុងសង្គម និងការអប់រំសហសម័យនោះ មនោនិយមស្វែងរកការបង្កើតសាលារៀន ដែលជាមជ្ឈមណ្ឌលនៃការបង្រៀន និងការរៀនប្រកបដោយបញ្ញា។ វាមើលឃើញថា គ្រូបង្រៀនជាភ្នាក់ងារដ៏សំខាន់ក្នុងការដឹកនាំសិស្សឱ្យដឹងពីសក្តានុពលបញ្ញាពេញលេញបំផុតរបស់ពួកគេ និងវាលើកទឹកចិត្តគ្រូបង្រៀន និងសិស្សរបស់ពួកគេឱ្យជួបប្រទះនិងពេញចិត្តចំពោះសមិទ្ធផលដ៏ល្អបំផុត និងយូរអង្វែងបំផុតនៃវប្បធម៌។ គ្រូ*

បង្រៀនណែនាំ សិស្សឱ្យស្គាល់សិល្បៈបុរាណ ស្នាដៃសិល្បៈ អក្សរសិល្ប៍និងតន្ត្រីដ៏អស្ចារ្យ និងយូរអង្វែង ដើម្បីឱ្យពួកគេទទួលបានបទពិសោធន៍ និងចែករំលែកនៅក្នុងតម្លៃវប្បធម៌ដែលស្នាដៃទាំងនេះបង្ហាញ។

ទោះបីបច្ចេកវិទ្យា អាចផ្ទេរឱ្យសិស្សនូវស្នាដៃអក្សរសិល្ប៍ និងសិល្បៈដ៏អស្ចារ្យក៏ដោយ ក៏ពួកមនោនិយមទទួចថា បច្ចេកវិទ្យាប្រើប្រាស់ជាមធ្យោបាយមួយនៃការអប់រំ ជាជាងគោលបំណងមួយ។ ខ្លឹមសារ មានសារៈសំខាន់បំផុត មិនមែនឧបករណ៍ខាងបច្ចេកទេស ដែលបង្ហាញឱ្យឃើញវានោះទេ។

**ខ-មេរៀនតាមពួកមនោនិយម**

តើគ្រូបង្រៀនម្នាក់ អាចប្រើប្រាស់មនោនិយមក្នុងការអភិវឌ្ឍមេរៀន? គ្រូបង្រៀនសិក្សាសង្គមថ្នាក់ទី៥ អាចពន្យល់ពីថាមពលនៃគំនិត និងច្បាប់ក្រមសីលធម៌កម្រិតខ្ពស់ តាមខ្លឹមសារមេរៀនពីជីវិត និងឥទ្ធិពលខាងសីលធម៌របស់លោក Mohandas Gandhi ដែលជាបិតា នៃឯករាជ្យភាពរបស់ឥណ្ឌា។ សិស្សនឹងសិក្សាជីវប្រវត្តិរបស់Gandhi ហើយនិងឆ្លុះបញ្ចាំងទៅលើគោលការណ៍នៃការជំទាស់ ដោយអហិង្សាប្រឆាំងនឹងអយុត្តិធម៌ ដែលបាននាំឱ្យចលនារបស់គាត់ប្រឆាំងនឹងពូជសាសន៍និយមក្នុងទ្វីបអាហ្វ្រិកខាងត្បូង និងអាណានិគមនិយមអង់គ្លេស នៅប្រទេសឥណ្ឌា។

## ៣-តថនិយម

### ពិភពតថនៃអត្ថវត្ថុ

ទស្សនវិទូក្រិកបុរាណ Aristotle បានអភិវឌ្ឍតថនិយម ដែលបានសង្កត់ធ្ងន់ទៅលើចំណេះដឹង និងតម្លៃសត្យានុម័ត។ ដូចដែលបានរៀបរាប់ក្នុងមេរៀនមុន Thomas Aquinas ក្នុងមជ្ឈិមសម័យបានបង្ហាញឱ្យគេដឹងនូវតថភាពខាងសាសនាជាច្រើន ដែលត្រូវបានគេស្គាល់ថាជាថមនិយម (Thomism) ជាសម្មតិកម្មមួយនៃលទ្ធិ Aristotelianism និង Christian។ Alfred North Whitehead បានបន្តប្រពៃណីពួកតថនិយម នៅដើមសតវត្សទី២០។ តថនិយមយល់ឃើញថា៖

1-មានពិភពនៃអត្ថិភាពពិត មិនបានបង្កើតឡើងដោយមនុស្សលោក។

2-ចិត្តមនុស្ស អាចដឹងអំពីពិភពពិត។

3-ចំណេះដឹងបែបនេះ ជាមគ្គុទ្ទេសក៍គួរឱ្យទុកចិត្តបានបំផុត ចំពោះអាកប្បកិរិយាបុគ្គល និងសង្គម។

**៣-១-បញ្ញត្តិជាគន្លឹះ**

**ក-ការចេះដឹង៖ ឥន្ទ្រីយារម្មណ៍បន្ទាប់មកការគិតអរូបី**

**បរមត្ថវិទ្យា និងពុទ្ធិវិទ្យា** ពួកតថនិយមជឿទៅលើពិភពសម្ភារៈ ដែលមានលក្ខណៈឯករាជ្យ និងនៅក្រៅចិត្តនៃអ្នកចេះ

ដឹង[3]។ អង្គវត្ថុទាំងអស់ ត្រូវបានបង្កើតឡើងពីសម្ភារៈ។ បន្តិចម្តងៗ សម្ភារៈ បានសន្មតនូវរចនាសម្ព័ន្ធនៃវត្ថុពិសេស។

មនុស្សលោក អាចដឹងវត្ថុទាំងនេះបាន តាមសរីរាង្គវិញ្ញាណ និងវិចាររបស់ពួកគេ។ ការចេះដឹង គឺជាលំនាំមួយ ដែលពាក់ព័ន្ធដល់ដំណាក់កាល២ គឺឥន្ទ្រីយារម្មណ៍ និងការគិតអរូបី។ ជាបឋម អ្នកចេះដឹងថា មានវត្ថុមួយ ហើយកត់ត្រាទិន្នន័យ អំពីវានៅក្នុងចិត្ត ដូចជាពណ៌ ទំហំ ទម្ងន់ ក្លិន និងសំឡេង។ ចិត្តរៀបចំដាក់ទិន្នន័យទាំងនេះទៅជាគុណភាព ដែលតែងតែបង្ហាញនៅក្នុងវត្ថុ ហើយនិងគុណភាពទាំងនោះ ជួនកាលក៏បានបង្ហាញខ្លួនផងដែរ។ តាមការកំណត់អត្តសញ្ញាណគុណភាពដ៏ចាំបាច់នោះ សិស្សបង្កើតបញ្ញត្តិនៃវត្ថុមួយ ហើយស្គាល់វាថាជាការស្ថិតនៅក្នុងក្រុមមួយដ៏ពិតប្រាកដ។ ការធ្វើចំណាត់ថ្នាក់នេះ ទុកឱ្យសិស្ស យល់ថា វត្ថុមួយបែងចែកគុណភាពពិតប្រាកដ ជាមួយសមាជិកផ្សេងទៀត នៅក្នុង ថ្នាក់តែមួយ ប៉ុន្តែ មិនមែនវត្ថុទាំងឡាយ នៅក្នុងថ្នាក់ផ្សេងទៀតទេ។

**ខ-កម្មវិធីសិក្សាដែលបានរៀបចំតាមមុខវិជ្ជា**

ដូចជាពួកមនោនិយម ពួកតថនិយម ជឿជាក់ថា ការអនុវត្តតាមកម្មវិធីសិក្សាមួយ ដែលមានមុខវិជ្ជាដោយឡែក ត្រូវបានរៀបចំរួចហើយ ជារបៀបសិក្សាដ៏មានប្រសិទ្ធភាពបំផុត អំពីតថភាព។ ការរៀបចំកម្មវត្ថុតាមមុខវិជ្ជា ដូចដែលអ្នកវិទ្យាសាស្ត្រ និងអ្នកប្រាជ្ញអនុវត្តនោះ ជាវិធីចាត់ថ្នាក់វត្ថុប្រកបដោយភាពជឿនលឿន។

ជាឧទាហរណ៍ បទពិសោធពីអតីតកាលរបស់មនុស្ស អាចត្រូវបានរៀបចំទៅជាប្រវត្តិសាស្ត្រ។ ភូតគ្រាមសាស្ត្រ សិក្សារុក្ខជាតិជាប្រព័ន្ធ ដោយយោងទៅតាមការចាត់ថ្នាក់របស់វា។ អង្គការនយោបាយ ដូចជា ជាតិ រដ្ឋាភិបាល អង្គនីតិបញ្ញត្តិ និងប្រព័ន្ធតុលាការ អាចត្រូវបានចាត់ថ្នាក់ទៅជាវិទ្យាសាស្ត្រនយោបាយ។ តថវិទូ ទាមទារឱ្យមានចំណេះដឹង អំពីតថភាព តាមការសិក្សាជាប្រព័ន្ធ ទៅជាមុខវិជ្ជាទាំងនេះ។

**គ-អាកប្បកិរិយា ប្រកបដោយវិចារណញ្ញាណ ផ្អែកទៅលើតថភាព**

**វិទ្យាសាស្ត្រសីលធម៌** ក្នុងបញ្ញត្តិនៃចំណេះដឹងរបស់តថវិទូនោះ ក្បួនច្បាប់ពិតប្រាកដ គ្រប់គ្រងអាកប្បកិរិយាប្រកបដោយភាពឈ្លាសវៃ។ ជាឧទាហរណ៍ មនុស្សគួរតែប្រព្រឹត្ត តាមរបៀបមួយប្រកបដោយវិចារណញ្ញាណ ហើយអាកប្បកិរិយា មានលក្ខណៈប្រកបដោយវិចារណញ្ញាណ នៅពេលណាវាអនុលោមទៅតាមរបៀបមួយ ដែលវត្ថុមានមុខងារទៅតាមតថភាព។ តាមការសិក្សាពីតថ

---

[3] William P. Alston, Araelist, *Conception of Truth* (Ithaca, NY: Cornell University Press,1996).

ភាពរបស់គេ មនុស្ស អាចអភិវឌ្ឍទ្រឹស្តីដោយពឹងផ្អែកទៅតាមច្បាប់ធម្មជាតិ រាងកាយ និងសង្គម។ ច្បាប់ធម្មជាតិ មានលក្ខណៈសកល និងអនន្ត ព្រោះតម្លៃពឹងផ្អែកទៅលើវា។

**ឃ-តក្កវិទ្យាបែបអនុមានញែក និងអនុមានរួម**

**តក្កវិទ្យា** គ្រូបង្រៀនតាមបែបតថនិយម ជាញឹកញាប់ប្រើទាំងអនុមានរួម និងញែក។ ឧទាហរណ៍ សិស្សក្នុងថ្នាក់ភូតគ្រាមសាស្ត្រ អាចពិនិត្យមើលផ្កាកុលាបដែលខុសគ្នាទៅតាមពណ៌ ក្លិន និងទំហំ ប៉ុន្តែ តាមអនុមានរួម សន្និដ្ឋានថា ទាំងអស់ជាសមាជិកនៃការបែងចែកអម្បូររុក្ខជាតិ ឬសត្វតែមួយ។ ទោះជាយ៉ាងនេះក្តី នៅពេលដែលសិស្សក្នុងថ្នាក់ដាំរុក្ខជាតិ ផ្កាកុលាបក្នុងសួនមួយ ទៅលើផ្ទៃដីក្នុងសាលារៀន ជាគម្រោងមួយនោះ សិស្សអាចពិភាក្សា ប្រវត្តិការថែទាំរុក្ខជាតិ ហើយធ្វើអនុមានញែក ទៅលើទីតាំងដ៏ត្រឹមត្រូវ ហើយនិងបរិមាណដី និងទឹក សម្រាប់ផ្កាកុលាប ដែលគេបានដាំ។

**៣-២-សំណួរជាមូលដ្ឋាន**

**ក-ចំណេះដឹងដែលពាក់ព័ន្ធវត្ថុ**

ដើម្បីចាប់ផ្តើមការសួរ ដោយប្រុងប្រយ័ត្នតាមបែបទស្សនវិជ្ជា (Philosophical cross-examination) យើងសួរជាថ្មី អ្វីជាចំណេះដឹង? តថវិទូ អាចនឹងឆ្លើយថា ចំណេះដឹង អាចពាក់ព័ន្ធនឹងពិភពរូបនិយម (The physical world) ដែលយើងរស់នៅ។ នៅពេលដែលយើងស្គាល់អ្វីមួយ ចំណេះដឹងរបស់យើងគឺតែងតែនិយាយអំពីវត្ថុ។ បញ្ញត្តិរបស់យើង អាចយកជាការបាន នៅពេលដែលវាពាក់ព័ន្ធវត្ថុទាំងនោះ ព្រោះវាពិតជាកើតមានក្នុងលោកយើងនេះ[4]។

**ខ-ការអប់រំតាមកម្មវត្ថុមុខវិជ្ជាសិក្សា**

តថនិយមវិទូ គួរនិយាយថា ការអប់រំក្នុងប្រព័ន្ធ ជាការសិក្សាពីចំណេះដឹង ដែលបានរៀបចំ និងចាត់ថ្នាក់ ទៅជាមុខវិជ្ជាដែលមានកម្មវត្ថុសិក្សាត្រឹមត្រូវ។ ប្រវត្តិវិទ្យា ភាសាវិទ្យាសាស្ត្រ និងគណិតវិទ្យា ជាអង្គពុទ្ធិដែលមានការៀបចំត្រឹមត្រូវ។ ប្រសិនបើយើងបានស្គាល់វាបានច្បាស់លាស់ យើងនឹងចេះដឹងថែមទៀត អំពីពិភពដែលយើងរស់នៅ។ ចំណេះដឹងនេះ គឺជាមគ្គុទ្ទេសក៍ប្រសើរបំផុតក្នុងការដឹកនាំកិច្ចការ ក្នុងជីវិតប្រចាំថ្ងៃរបស់យើង។

តថវិទូ មើលឃើញសាលារៀន ថាជាស្ថាប័នសិក្សាបឋម ដែលសង្គមបង្កើតឡើង ដើម្បីផ្តល់ឱ្យសិស្សជាមួយពុទ្ធិ អំពីពិភពសត្យានុម័ត។ ពីព្រោះតែមនុស្សទាំងអស់ មានសក្តានុពលខាងវិចារណញ្ញាណនោះ គួរតែអាចធ្វើបានចំពោះទាំងអស់គ្នា ដោយមាន

[4] Andrew Newman,. *The Correspondence Theory of Truth: An Essay on the Methaphysics of Prediction* (New York: Cambridge University Press, 2002).

*សិស្សទាំងអស់គ្នា បានបន្តកម្មវិធីសិក្សាតែមួយដែលនឹងរៀបចំពួកគេ ដើម្បីធ្វើការសម្រេចចិត្ត ប្រកបដោយវិចារណញ្ញាណ។*

**៣-៣-ការអនុវត្តចំពោះគ្រូបង្រៀនក្នុងថ្នាក់នាពេលបច្ចុប្បន្ន**

**ក-ថ្នាក់រៀនសម្រាប់សិក្សាមិនមែនជាការព្យាបាលរោគទេ**

*ក្នុងថ្នាក់រៀនតថនិយម ការទទួលខុសត្រូវរបស់គ្រូជាលើកដំបូង គឺត្រូវបង្រៀនបំណិន ដូចជា ការអាន ការសរសេរ ឬការគិតគណនា ឬអង្គពុទ្ធិទៅតាមមុខវិជ្ជាមួយចំនួនដូចជាប្រវត្តិវិទ្យា គណិតវិទ្យា ឬវិទ្យាសាស្ត្រ។ ទោះបីជាគេវាយតម្លៃថា សិស្សរបស់ខ្លួនគាត់ជាមនុស្ស ដែលមានចិត្តរំភើប ព្រមទាំងវិចារណញ្ញាណក៏ដោយ ក៏គ្រូបង្រៀនបែបតថនិយម មិនប្រែក្លាយថ្នាក់រៀន ទៅជាមជ្ឈមណ្ឌលព្យាបាលរោគ សម្រាប់ការកែតម្រូវអាកប្បកិរិយា ឬចិត្តរំភើប។ គ្រូបង្រៀនបែបតថនិយម គួរតែប្រឆាំងជំទាស់ទៅ នឹងសកម្មភាព ដែលមិនមែនជាការសិក្សា ដែលជ្រៀតជ្រែកដល់គោលបំណងបឋមរបស់សាលារៀន ជាមជ្ឈមណ្ឌលនៃការសិក្សា។*

**ខ-គ្រូជាអ្នកជំនាញការកម្មវត្ថុសិក្សាក្នុងមុខវិជ្ជា**

*ដើម្បីទទួលខុសត្រូវការអប់រំ នៅបឋមសិក្សា គ្រូបង្រៀនបែបតថនិយម ត្រូវតែចេះច្បាស់លាស់ នូវមុខវិជ្ជារបស់ខ្លួន។ ឧទាហរណ៍ គ្រូបង្រៀនប្រវត្តិវិទ្យា គួរតែជាប្រវត្តិវិទូ ដោយចេះមុខវិជ្ជានោះ ច្បាស់លាស់ពីពេលមុន។ ជាងនេះទៀត គ្រូបង្រៀនបែបតថនិយម គួរតែមានការអប់រំទូទៅខាងសិល្បៈសេរី និងវិទ្យាសាស្ត្រ ដែលអាចឱ្យពួកគេបកស្រាយទំនាក់ទំនងរវាងផ្នែកកោសល្យវិច័យ និងកម្មវត្ថុសិក្សាតាមមុខ វិជ្ជាផ្សេងទៀត។ គ្រូបែបតថនិយម អាចប្រើប្រាស់វិធីអ្វីដែលខ្លួនចេះ និងត្រៀមបង្រៀនយ៉ាងទូលំទូលាយ ដូចជាបទឧទ្ទេស ការពិភាក្សា ការបកស្រាយបញ្ជាក់ ឬការពិសោធ។ ចំណេះចំណានខាងខ្លឹមសារ មានសារៈសំខាន់ណាស់ ហើយវិធីសាស្ត្រគឺជាមធ្យោបាយចាំបាច់ តែក៏អាចបន្ទាប់បន្សំ ដើម្បីសម្រេចបានគោលដៅនោះ។*

**គ-គំរូនៃគោលវិធីបែបតថនិយម**

*តើគ្រូបង្រៀនរូបវិទ្យា នៅមធ្យមសិក្សាដោយមានការតម្រង់ទិសទស្សនវិជ្ជាបែបតថនិយម អាចធ្វើផែនការទៅលើមេរៀនមួយស្តីពីច្បាប់ចលនារបស់ញូតុន* (Newton) *យ៉ាងដូចម្តេច?*

1-*គ្រូគួរតែជួយសិស្សសិក្សាពីបរិបទជាប្រវត្តិ ហើយអធិប្បាយនូវការរួមចំណែកខាងវិទ្យាសាស្ត្ររបស់គាត់។*

2-*គ្រូអាចពន្យល់ច្បាប់ចលនា តាមការបកស្រាយក្នុងមន្ទីរពិសោធន៍។*

3-*សិស្ស អាចពិភាក្សាការបកស្រាយ និងធ្វើទូទៅកម្មបែបវិទ្យាសាស្ត្រ ដែលវាបានពន្យល់។*

4-ជាចុងក្រោយ សិស្សគួរតែធ្វើតេស្ត ដើម្បីបកស្រាយការយល់ដឹង ពីច្បាប់ចលនារបស់លោកញូតុន[5]។

### ឃ-ស្តង់ដា និងការវាយតម្លៃ

តថវិទូ គួរតែសាទរចលនា ដើម្បីកំណត់ស្តង់ដា ដែលបញ្ជាក់គោលដៅស្នាដៃសិក្សារបស់សិស្ស ពិសេសក្នុងផ្នែកបំណិន ដូចជាការអាន និងក្នុងផ្នែកខ្លឹមសារមុខវិជ្ជា ដូចជា គណិតវិទ្យា វិទ្យាសាស្ត្រ និងប្រវត្តិវិទ្យា។ តេស្តដែលប្រកបដោយស្តង់ដា ផ្តល់ទិន្នន័យដ៏លំបាក និងអាចប្រៀបធៀបបាន អំពីរបៀបដែលសិស្ស មានចំណេះដាក់លាក់លើមុខវិជ្ជា តាមកម្មវិធីសិក្សាបានល្អប៉ុណ្ណា និងរបៀបដែលគ្រូ កំពុងបង្រៀនសិស្សបានល្អប៉ុណ្ណា។ ស្តង់ដា ជួយរក្សាសាលារៀន និងគ្រូបង្រៀន ដែលអាចពន្យល់បាន។

តថនិយមវិទូ យល់ស្របនឹងការប្រើប្រាស់បច្ចេកវិទ្យា ដែលបំពេញបន្ថែមវិធីទាំងឡាយផ្សេងទៀតនៃការអភិវឌ្ឍបំណិន និងសមត្ថភាពកម្មវត្ថុសិក្សាតាមមុខវិជ្ជា។ ពួកគេចង់បានកម្មវិធីដែលមានលក្ខណៈតថនិយម និងមានប្រសិទ្ធភាពតាមអាចធ្វើបាន។

## សន្និដ្ឋាន

ទ្រឹស្តីមនោរនិយម ដែលទទួលបានពីការទ្រដោយលោក Emerson, Froebel, Hegel, និងPlato ជាទ្រឹស្តីសំខាន់មួយដែលត្រូវបានគេយកទ្រឹស្តីទស្សនវិជ្ជា ទៅប្រតិបត្តិក្នុងវិស័យអប់រំ ដើម្បីរៀបចំអភិវឌ្ឍកម្មវត្ថុសិក្សានៃកម្មវិធីសិក្សាដោយសង្កត់ធ្ងន់ទៅលើគំនិតដែលស្ថិតនៅយូរអង្វែង និងដ៏មានតម្លៃនៅក្នុងវប្បធម៌ខ្លួន។

ទ្រឹស្តីតថនិយម ដែលទទួលបានពីការគាំទ្រដោយលោក Aquinas, Aristotle, Broudy, Maritain និង Pestalossi ជាទ្រឹស្តីសំខាន់មួយដែលត្រូវបានគេយកទ្រឹស្តីទស្សនវិជ្ជា ទៅប្រតិបត្តិក្នុងវិស័យអប់រំ ដើម្បីរៀបចំអភិវឌ្ឍកម្មវត្ថុសិក្សានៃកម្មវិធីសិក្សាដោយសង្កត់ធ្ងន់ទៅមុខវិជ្ជាបែបវិទ្យាសាស្ត្រនិងបែបមនុស្សនិយម។

[5] Philip H. Phenic, *Philosophies of Education* (New York: Wiley, 1961), pp.22-24.

# ឯកសារយោង

1- Gerald L. Gutek, *Philosophical and Ideological Voices in Education*, Boston: Allyn and Bacon, 2004.
2- Gerald L. Gutek, *Philosophical and Ideological Perspectives on Education*, 2nd ed., Boston: Allyn and Bacon, 1997.
3- William P. Alston, Araelist, *Conception of Truth*, Ithaca, NY: Cornell University Press,1996.
4- Andrew Newman,. *The Correspondence Theory of Truth: An Essay on the Methaphysics of Prediction* New York: Cambridge University Press, 2002.
5- Philip H. Phenic, *Philosophies of Education*, New York: Wiley, 1961.
6- Allan C. Ornstein et al., *Foundation of Education*, Wadsworth, Canada. 2008.
7- Allan C. Ornstein et al., *Foundation of Education*, Wadsworth, Canada. 20011.